# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការឪឡឹក
# តាខ្មៅ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០
## ចូរធ្វើដូច្នេះ ដើម្បីរំឭកដល់ខ្ញុំ

**អត្ថបទទី១៖ សេរីភាព ១២,១-១៤**

នៅពេលបរិភោគ ត្រូវក្រវាត់ចង្កេះ ពាក់ស្បែកជើង កាន់ដំបង ដូចរៀបចំខ្លួនចេញដំណើរ ហើយត្រូវបរិភោគឲ្យរហ័ស។ សរ ១២,១១

**អត្ថបទទី២៖ កូរិនថូសទី១ ១១,២៣-២៦**

រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ។ ១ករ ១១,២៦

**ដំណឹងល្អ៖ យ៉ូហាន ១៣,១-១៥**

បើខ្ញុំជាព្រះអម្ចាស់ និងជាព្រះគ្រូ បានលាងជើងឲ្យអ្នករាល់គ្នាទៅហើយ អ្នករាល់គ្នាក៏ត្រូវតែលាងជើងឲ្យគ្នាទៅវិញទៅមកដែរ។ យហ ១៣,១៤

បងប្អូនជាទីស្រឡាញ់!

យប់នេះ យើងចូលរួមជាអង្គតែមួយរួមជាមួយព្រះសហគមន៍នៅក្នុងពិភពលោក រួមជាមួយព្រះសហគមន៍នៅប្រទេសកម្ពុជា។ ជាពិសេស សម្រាប់មណ្ឌលសកម្មភាពទាំង៩នៅក្នុងភូមិភាគភ្នំពេញ ដើម្បីចូលរួមនៅក្នុងពិធីជប់លៀងចុងក្រោយរបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ។ ខ្ញុំបានអញ្ជើញឲ្យបងប្អូនអធិដ្ឋានសម្រាប់លោកបូជាចារ្យ ដោយសារថ្ងៃនេះជាថ្ងៃដែលយើងជូនពរដល់លោកបូជាចារ្យ ដែលបានទទួលអគ្គសញ្ញាតែងតាំងដើម្បីបម្រើតាមរបៀបព្រះយេស៊ូ។

គម្ពីរដែលយើងបានស្តាប់ថ្ងៃនេះ ចាប់ផ្តើមដោយលោកយ៉ូដាស់អ៊ីស្ការីយ៉ូត ជាមិត្តសម្លាញ់របស់ព្រះយេស៊ូនិងបានក្បត់ព្រះអង្គ។ នៅពេលនោះ ព្រះយេស៊ូបាននៅជាមួយក្រុមគ្រីស្តទូតតែ១១នាក់មុនពេលគេចាប់ព្រះយេស៊ូ ជាពិធីជប់លៀងចុងក្រោយជាមួយក្រុមគ្រីស្តទូតដែលជាមិត្តសម្លាញ់ជិតស្និទ្ធរបស់ព្រះអង្គ ដែលព្រះអង្គបានជ្រើសរើស។ ដូច្នេះ នេះជាពេលវេលាដែលក្រុមគ្រីស្តទូតនិងព្រះយេស៊ូជិតស្និទ្ធបំផុត ព្រះអង្គដឹងថាជិតដល់ពេលវេលាដែលព្រះអង្គត្រូវសោយទិវង្គត។ ព្រះយេស៊ូ បានយកពេលដើម្បីអប់រំចុងក្រោយដល់ក្រុមគ្រីស្តទូត នៅពេលនោះព្រះយេស៊ូបានយកនំប៉័ងនិងស្រា និងបានចែករំលែករូបកាយនិងលោហិតរបស់ព្រះអង្គ ដើម្បីចិញ្ចឹមជីវិតរបស់ក្រុមគ្រីស្តទូត ជីវិតរបស់យើងខ្ញុំដែលជួនកាលមានទុក្ខលំបាក មានទុក្ខវេទនា ប៉ុន្តែជាជីវិតដែលជាព្រះអំណោយទានពីព្រះជាម្ចាស់ផ្ទាល់។

យប់នេះ ព្រះអង្គបានអញ្ជើញយើងនៅក្នុងបដិវត្តន៍ដ៏អស្ចារ្យមែនទែន ដែលណែនាំឲ្យសង្គមបានប្រែប្រួលចាប់ពីព្រះយេស៊ូបានជប់លៀងជាមួយក្រុមសាវ័ក។ បពិត្រព្រះអម្ចាស់ដែលជាព្រះគ្រីស្ត ដែលបានទទួលប្រេងអភិសេកពីព្រះអម្ចាស់ នៅពេលនោះព្រះអង្គបានលុតជង្គង់នៅមុខក្រុមគ្រីស្តទូត ដើម្បីលាងជើងឲ្យក្រុមគ្រីស្តទូត។ បពិត្រព្រះអម្ចាស់ដែលជាព្រះបុត្រារបស់ព្រះអង្គ ជាព្រះគ្រូដែលបានព្យាបាលណែនាំឲ្យគេមានជីវិតសាជាថ្មី ដែលបានសង្គ្រោះដែលបានលើកលែងទោស នៅពេលនោះបានចងក្រមានៅចង្កេះដើម្បីបម្រើក្រុមគ្រីស្តទូតផ្ទាល់។ បពិត្រព្រះអម្ចាស់ដែលជាបុត្រមនុស្ស នៅពេលនោះព្រះអង្គបានបង្គាប់ឲ្យយើងធ្វើតាមព្រះអង្គ នេះជាការអស្ចារ្យចុងក្រោយរបស់ព្រះអង្គមុនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ដូច្នេះយប់នេះយើងមិនធ្វើតាមចិត្តយើងផ្ទាល់ យប់នេះព្រះយេស៊ូបង្គាប់ឲ្យយើង "**ខ្ញុំបានធ្វើជាគំរូឲ្យអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា**"។ បពិត្រព្រះអម្ចាស់ ចាប់ពីពេលនេះតទៅអ្វីៗទាំងអស់បានប្រែប្រួល អ្វីៗទាំងអស់បានក្លាយជាថ្មីនៅក្នុងរបៀបថ្មី ទំនាក់ទំនងនៅក្នុងសង្គម ទំនាក់ទំនងនៅក្នុងក្រុមគ្រួសារ ទំនាក់ទំនងនៅក្នុងជីវិតរបស់យើងជាមួយព្រះអម្ចាស់ និងជាមួយគ្នានិងគ្នា។

នំប៉័ងនិងស្រា ដែលបានក្លាយទៅជាព្រះកាយនិងព្រះលោហិត គឺជាជីវិតដែលព្រះយេស៊ូបានបូជានៅលើឈើឆ្កាងដើម្បីសង្គ្រោះយើង នៅពេលនោះព្រះយេស៊ូបានណែនាំឲ្យព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ភ្ជាប់នឹងដួងចិត្តទន់ខ្សោយរបស់យើងជាមនុស្ស។ ពិតមែនយើងបានស្តាប់ថា "**ដោយព្រះអង្គបានស្រឡាញ់សាវ័ករបស់ព្រះអង្គដែលរស់នៅក្នុងលោកនេះ ទ្រង់ស្រឡាញ់គេរហូតដល់ទីបំផុត**"។ នៅពេលនេះ ពិភពលោករបស់យើងកំពុងរស់នៅក្នុងការប្រែប្រួល ណែនាំឲ្យសង្គមរបស់យើងប្រែប្រួល ណែនាំឲ្យសេដ្ឋកិច្ចរបស់យើងប្រែប្រួល ណែនាំឲ្យនយោបាយរបស់យើងប្រែប្រួល ណែនាំឲ្យទំនាក់ទំនងប្រែប្រួល ណែនាំឲ្យអ្វីៗទាំងអស់ដែលយើងធ្លាប់ស្គាល់ពីមុន ដោយសារកូវីដ១៩បីដូចជាប្រែប្រួលអស់ហើយ។ សម្រាប់ប្រទេសកម្ពុជាយើង ដែលមិនសូវមានអ្នកជំងឺនេះច្រើន តែយើងដឹងថាយើងនឹងទទួលឥទ្ធិពលលើសេដ្ឋកិច្ច លើជីវិតប្រចាំនៃប្រជារាស្ត្ររបស់យើងដែរ។

ប៉ុន្តែ ទោះបីមុនកូវីដ១៩និងក្រោយកូវីដ១៩ យើងដឹងថាអ្វីដែលព្រះយេស៊ូបានណែនាំឲ្យប្រែប្រួលអស់ហើយនៅក្នុងយប់នេះ ទៅជាមូលដ្ឋានគ្រឹះនៃពិភពលោក។ សម្រាប់យើងជាគ្រីស្តបរិស័ទ ជាមូលដ្ឋានគ្រឹះរបស់យើងចាប់ពីពេលនេះតទៅ គឺយើងជាបងប្អូនគ្នាដែលបម្រើគ្នាទៅវិញទៅមក។ យើងមិនរើសមនុស្សដែលយើងនឹងបម្រើ យើងដឹងថានេះជាបង្គាប់របស់ព្រះយេស៊ូបម្រើគ្នាទៅវិញទៅមក ចាប់ពេលនេះតទៅយើងជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ នៅក្នុងក្រុមគ្រី

ស្តទូតមាន១២នាក់ ប៉ុន្តែមានតែម្នាក់ដែលបានក្បត់ព្រះយេស៊ូ។ ដូច្នេះ យើងអធិដ្ឋានដើម្បីឲ្យយើងជាគ្រីស្តបរិស័ទនៅក្នុងភូមិភាគភ្នំពេញ នៅប្រទេសកម្ពុជាទាំងមូល ឲ្យយើងទៅជាគ្រីស្តទូត១១នាក់ដែលមិនក្បត់ព្រះយេស៊ូ ដែលភ្ជាប់ជាមួយព្រះយេស៊ូ និងដែលសុខចិត្តបម្រើបងប្អូនឯទៀតៗ ជាមូលដ្ឋានអាទិភាពនៃជីវិតរបស់យើងជាប្រចាំ។ ចាប់ពីពេលនេះតទៅ ឲ្យយើងយកក្រមាមកក្រវាត់ចង្កេះរបស់យើង ដើម្បីលាងជើង ដើម្បីបម្រើបងប្អូនឯទៀតៗ។

សម្រាប់ក្រុមយុវជនទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ខ្ញុំបានរៀបចំលក្ខខណ្ឌមួយដែលមាន៧ចំណុច ដោយដឹងថាយើងជាអ្នកបម្រើ និងយើងជាទាហានរបស់ព្រះជាម្ចាស់៖

- ✓ ទាហានរបស់ព្រះជាម្ចាស់ គឺជាអ្នកស្ម័គ្រចិត្ត ជាអ្នកបម្រើព្រះជាម្ចាស់ ដោយកិត្តិយស និងដោយភក្ដីភាព។
- ✓ ទាហានព្រះជាម្ចាស់ម្នាក់ ជាបងប្អូនគ្នាដោយមិនប្រកាន់សញ្ជាតិឡើយ អ្នកគប្បីមានសមត្ថភាពដោយស្ម័គ្រចិត្តចំពោះគ្នាជានិច្ច ដោយត្រូវបង្រួបបង្រួមគ្នាជាសមាជិកគ្រួសារតែមួយ។
- ✓ ចូរគោរពប្រពៃណី ចូរស្តាប់ប្រធាន ចូរគោរពវិន័យ និងមិត្តភាពគឺជាកម្លាំងរបស់អ្នក សេចក្តីអង់អាចក្លាហាននិងសេចក្តីសុចរិត គឺជាគុណធម៌របស់អ្នក។
- ✓ ចូរមានមោទនភាពនៅក្នុងនាមជាទាហានរបស់ព្រះជាម្ចាស់ ចូរបង្ហាញមោទនភាពនេះតាមរយៈឯកសណ្ឋានដ៏ស្រស់ស្អាតរបស់អ្នកជានិច្ច តាមរបៀបបម្រើគ្នាទៅវិញទៅមក និងតាមរបៀបដាក់ខ្លួន។
- ✓ ចូរមានចិត្តស្រឡាញ់ស្មោះសរចំពោះគ្នាទៅវិញទៅមក ទាហានដ៏ចំណានរបស់ព្រះជាម្ចាស់ គឺអ្នកត្រូវរីកចំរើនខ្លួនឲ្យម៉ត់ចត់ អ្នកត្រូវរៀបចំចិត្តគំនិតឲ្យបានល្អថ្លៃថ្លាបំផុត អ្នកត្រូវយកចិត្តទុកដាក់លើរូបកាយ លើផ្លូវវិញ្ញាណរបស់អ្នកជានិច្ច។
- ✓ បេសកកម្ម គឺជាបេសកកម្មសក្ការៈ ដូច្នេះត្រូវតែបំពេញបេសកកម្មប្រកាសដំណឹងល្អរហូតដល់ទីបំផុត គឺរហូតដល់បូជាជីវិតរបស់ខ្លួននៅក្នុងករណីចាំបាច់។ ក្នុងពេលបំពេញបេសកកម្មប្រកាសដំណឹងល្អ ចូរប្រព្រឹត្តដោយគ្មានមនោសញ្ចេតនា ដោយគ្មានកំហឹង។
- ✓ ចូរគោរពឆន្ទៈរបស់ម្នាក់ៗ អ្នកមិនត្រូវបោះបង់បងប្អូននៅក្នុងពេលមានគ្រាអាសន្នវេទនាឡើយ ចូរអធិដ្ឋាននិងត្រៀមខ្លួនបម្រើជានិច្ច។

បពិត្រព្រះអម្ចាស់ យប់នេះយើងស្ម័គ្រចិត្តយាមអធិដ្ឋានជាមួយព្រះអង្គពេញមួយយប់។ អាម៉ែន៕